ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ❀ ៤៤

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៩៦/សជណ ធទឧ

# សេចក្តីជូនដំណឹង
## ស្តីពី ស្ថានភាពទឹកទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់

បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកទន្លេមេគង្គ រួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ប្រព័ន្ធសម្ពាធទាបដែលបានកើតឡើង និងអូសកាត់ពីលើអាងទន្លេមេគង្គក្នុងប្រទេសថៃ និងប្រទេសឡាវ នាពេលកន្លងមកនោះ បច្ចុប្បន្នបានធ្វើដំណើររំកិលចុះមកទិសខាងត្បូង ( ក្បែរព្រំប្រទល់ប្រទេសកម្ពុជា-ឡាវ ) ។ ស្ថានភាពបែបនេះ បានធ្វើឱ្យរបាយទឹកភ្លៀង នឹងបន្តធ្លាក់ចុះជាបន្តបន្ទាប់ពីមធ្យមទៅច្រើន នៅក្នុងប្រទេសកម្ពុជា និងមានភ្លៀងធ្លាក់ពីតិចទៅមធ្យមនៅអាងទន្លេមេគង្គភាគខាងលើ ( ក្នុងប្រទេសឡាវ និងប្រទេសថៃ ) ។

យោងតាមស្ថានភាពអាកាសធាតុ និងរបាយទឹកភ្លៀង ដូចបានជម្រាបជូនខាងលើ នឹងបណ្តាលឱ្យ :

1- រដូវវស្សាឆ្នាំ 2014 នៅព្រះរាជាណាចក្រកម្ពុជា អាចនឹងបញ្ចប់នៅចុងសប្តាហ៍ទី 2 នៃខែវិច្ឆិកា ។

2- ក្នុងអំឡុងពេលពី 02 ទៅ 03 ថ្ងៃ ខាងមុខ កំពស់ទឹកទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ នឹងចាប់ស្រកចុះ ជាបន្តបន្ទាប់ ។

យោងលើស្ថានភាពកំពស់ទឹកទន្លេ ដូចបានជម្រាបជូនខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនបងប្អូនប្រជាកសិករ និងសូមអំពាវនាវដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី ដូចខាងក្រោម :

1- ការបង្កបង្កើនផលដំណាំកសិកម្មគ្រប់ប្រភេទ នៅតាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ អាចចាប់ផ្តើមបង្កបង្កើនផលបានចាប់ពីពេលនេះតទៅ ។

2- សូមក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ចូលរួមសហការជាមួយមន្ទីរធនធានទឹក និងឧតុនិយម រាជធានី-ខេត្ត ក្នុងការចាត់វិធានការណ៍រក្សាទឹកទុក សម្រាប់បម្រើដល់ការងារបង្កបង្កើនផល ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh